# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧

## មហោស្រពគីហ្សូណាជប៉ុន-កម្ពុជា២០១៧

ស្ថានទូតជប៉ុនរួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) មជ្ឈមណ្ឌលមូលនិធិជប៉ុននៅអាស៊ី នឹងរៀបចំនូវមហោស្រពគីហ្សូណាជប៉ុន-កម្ពុជាលើកទី៦ ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៧ នៅ CJCC។

កម្មវិធីសំខាន់ៗនៅក្នុងមហោស្រពនេះ មានដូចខាងក្រោម ៖

**- ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ**

*ម៉ោង១៨:៣០ ដល់ ម៉ោង២០:០០* *កម្មវិធីបើកមហោស្រព*

*(ដោយមានការចូលរួមពីសំណាក់ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ)*

**- ថ្ងៃសុក្រ ទី២៤ ខែកុម្ភៈ**

*ម៉ោង១៨:៣០ ដល់ម៉ោង១៩:៣០* *ការសម្តែងក្បាច់រាំទំនើបរបស់ជប៉ុនដោយក្រុម TEMPURA KIDZ*

**-ថ្ងៃសៅរ៍ ទី២៥ ខែកុម្ភៈ**

*ម៉ោង១៨:០០ ដល់ ១៩:៣០* *ការប្រគំតន្ត្រីដោយអ្នកចម្រៀងជប៉ុនដ៏ល្បីល្បាញ អ្នកស្រី Tokiko Kato នៅកម្ពុជាឆ្នាំ២០១៧*

**-ថ្ងៃអាទិត្យ ទី២៦ ខែកុម្ភៈ**

*ម៉ោង១៤:០០ដល់ ម៉ោង១៦:០០* *ការប្រកួតប្រជែងសម្លៀកបំពាក់យូកាតានៅកម្ពុជាឆ្នាំ២០១៧*

*ម៉ោង១៨:៣០ដល់ ម៉ោង២០:០០* *ការប្រគំតន្ត្រីក្លាស៊ីកមិត្តភាពជប៉ុន-កម្ពុជាលើកទី១០*

ក្រៅពីកម្មវិធីធំៗទាំងនេះ ក៏មានកម្មវិធីជាច្រើនផ្សេងទៀត ដូចជាការសម្តែងសិល្បៈ សិក្ខាសាលានៃការសម្តែងក្បាច់រាំទំនើបជប៉ុន ការបង្ហាញជូននូវកីឡាយុទ្ធសិល្ប៍ ការបង្ហាញម៉ូដសម្លៀកបំពាក់ ការស្លៀកពាក់បែបតុក្កតាជប៉ុន(ខូសផ្លេ) ការបង្ហាញជូននូវការគណនាលេខយ៉ាងរហ័យដោយប្រើក្បាច់គិតលេខបុរាណ សិល្បៈតុបតែងផ្កា និងការសរសេរអក្សផ្ចង់ ព្រមទាំងមានការធ្វើបបកថានានា និងការតាំងពិព័រណ៌ផ្សេងៗជាដើម នៅក្នុងមហោស្រពនេះ។ ខិតប័ណ្ណដែលមានកម្មវិធីលំអិតគឺមានភ្ជាប់ជូននៅក្នុងសេចក្តីប្រកាសនេះ។

ប្រធានបទក្នុងឆ្នាំនេះគឺធ្វើដំណើរទៅកាន់ប្រទេសជប៉ុន "Fly to Japan" ។ ប្រធានបទនេះគឺជាការស្វាគមន៍ការហោះហើរត្រង់រវាងប្រទេសកម្ពុជា និងប្រទេសជប៉ុនកាលពីខែកញ្ញា ឆ្នាំ២០១៦ កន្លងទៅ។ យើងខ្ញុំសង្ឃឹមថាប្រធានបទក្នុងមហោស្រពនេះនឹងអាចអោយប្រជាជនកម្ពុជាមានអារម្មណ៍កាន់តែខិតមកជិតប្រទេសជប៉ុន ហើយជំរុញអោយពួកគេមានចំណាប់អារម្មណ៍ទៅលេងប្រទេសជប៉ុនផងដែរ។

សម្រាប់ការសាកសួរព័ត៌មាន សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាន នៃស្ថានទូតជប៉ុន ដែលមានទូរស័ព្ទលេខ០២៣ ២១៧ ១៦១ (លេខភ្ជាប់បន្ត ១១២១) ឬផ្ញើអ៊ីម៉ែលមកអាស័យដ្ឋាន info.jpn@pp.mofa.go.jp។ សម្រាប់ព័ត៌មានបន្ថែមស្តីពីមហោស្រពនេះ សូមចូលទៅកាន់ទំព័រហ្វេសប៊ុក "Japan Cambodia Kizuna" ៕

---